**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**
លេខសំណុំរឿងព្រហ្មទណ្ឌ: ៣១៦
ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ៣៦៤
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២
សាលក្រមលេខ: **៥០ (ឈ) ៥៥៣**
ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២

# ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តសៀមរាប សាលសវនាការ ខ១ កាលបរិច្ឆេទបើកសវនាការ ថ្ងៃព្រហស្បតិ៍ ៧កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦ ត្រូវនឹងថ្ងៃទី០៤ ខែសីហាឆ្នាំ២០២២ វេលាព្រឹក។
កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ វេលាព្រឹក។

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក ចៅក្រុមប្រឹក្សា
លោកស្រី ចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៣១៦ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ និង សំណុំរឿងជំនុំជម្រះលេខ ៣៦៤ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ដែលមានជនជាប់ចោទៈ

ឈ្មោះ [redacted] សុខ ភេទប្រុស កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ (អាយុ៤៦ឆ្នាំ) ជនជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ស្រេង "ស" ម្តាយឈ្មោះ [redacted] សៀកលីវ "រ" ប្រពន្ធឈ្មោះ [redacted] គីមហ៊ាង "ស" ទោសពីមុនៈ គ្មាន។ (**ក្នុងឃុំ**)

**ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខៈ** ២៣៨ (ច) ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២។

ត្រូវបានជាប់ចោទពីបទ ៖ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

- លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោះ [redacted] សុខ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៧៤ អយធ/២២ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។



Scanned with CamScanner

- បានឃើញ ដីកាដំណោះស្រាយលេខ ២១០២ ពស.ព្រស/ច ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៣៩២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

**អង្គហេតុកើតមានឡើងដូចតទៅ៖**

កាលថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០៥ និង ៣០ នាទី ឈ្មោះ [redacted] សុខ ភេទប្រុស អាយុ៤៦ឆ្នាំ បានធ្វើសកម្មភាពយកកាំបិតប៉ុងតោកាប់ទៅលើប្រពន្ធឈ្មោះ [redacted] គឹមហ៊ាង ភេទស្រី អាយុ៤៤ឆ្នាំ ត្រូវត្រង់កខាងស្ដាំបណ្ដាលឲ្យស្លាប់។ ក្រោយធ្វើសកម្មភាពរួចឈ្មោះ [redacted] សុខ បាន ជិះម៉ូតូទៅប្រាប់សមត្ថកិច្ច ថាខ្លួនបានសម្លាប់ប្រពន្ធហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដងតាមចម្លើយ របស់ឈ្មោះ [redacted] សុខ បានសារភាពថា នៅថ្ងៃកើតហេតុខ្លួនបានធ្វើសកម្មភាពរុញប្រពន្ធរបស់ខ្លួន ធ្លាក់ពីលើកាំជណ្ដើររួចយកកាំបិតប៉ុងតោកាប់សម្លាប់ប្រពន្ធប្រាកដមែន។

**សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

- ជនជាប់ចោទឈ្មោះ [redacted] សុខ បានធ្វើកំណត់សម្គាល់ថា: សូមឲ្យតុលាការធ្វើការបន្ធូរបន្ថយ ទោសដល់ខ្ញុំបាទផង។

- តំណាងអយ្យការបានសន្និដ្ឋានប្ដឹងសុំ ៖ ឆ្លងតាមកិច្ចពិភាក្សាដេញដោលរួចមកឃើញថាជន ជាប់ចោទពិតជា បានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន។ តាងនាមតំណាងអយ្យការសុំ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៧៤ អយធ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប និងប្ដឹងសុំឲ្យចៅក្រមជំនុំជម្រះផ្ដន្ទា ទោសជនជាប់ចោទតាមច្បាប់។

- លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោះ [redacted] សុខ បានធ្វើសេចក្ដី សន្និដ្ឋានការពារថា ៖ ឆ្លងការដេញដោល និងពិភាក្សាកូនក្ដីរបស់ខ្ញុំបាទបានឆ្លើយសារភាព និងមាន ភាពស្ដាយក្រោយចំពោះកំហុសរបស់ខ្លួន ចំពោះការសម្លាប់ប្រពន្ធដោយកាំបិតប៉ុងតោ ក្នុងនេះ ដែល ខ្ញុំបាទឯកភាពទៅនឹងការសន្និដ្ឋានរបស់តំណាងអយ្យការ។ ខ្ញុំបាទសូមស្នើសុំឲ្យតុលាការធ្វើ ការពិនិត្យទៅលើកូនក្ដីរបស់ខ្ញុំចំពោះជម្ងឺថប់អារម្មណ៍ មុនកូវីតកូនក្ដីខ្ញុំបាទមានការងារ និងប្រាក់ ចំណូលធម្មតា ប៉ុន្តែពេលកូវីតមកដល់គឺកូនក្ដីខ្ញុំបាទបានបាត់បង់ការងារ និងពុំមានប្រាក់ចំណូល នោះទេ។ បន្ថែមគឺនោះ នៅពេលកើតហេតុគឺគាត់មានជម្ងឺកូវីតបន្ថែម និងជម្ងឺតម្រង់នោមដែល មិនអាចនោមចេញ។ ម្យ៉ាងទៀតនៅពេល ដែលគេបញ្ជូនមកដល់ពន្ធនាគារគឺស្ថានភាពរបស់កូន ក្ដីខ្ញុំ គឺធ្ងន់ធ្ងរមិនអាចសូម្បីនិយាយបានទើបមន្ត្រីខាងពន្ធនាគារបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ បង្អែក ទើបឥឡូវមានសភាពធូរស្រាលខ្លះ។ ម្យ៉ាងទៀត សូមស្នើសុំឲ្យតុលាការពិនិត្យចំពោះការដឹង កំហុសរបស់កូនក្ដីខ្ញុំបាទ និងពិចារណាចំពោះស្ថានសម្រាលទោសមួយចំនួន និងចំពោះការព្យួរទោស មួយចំនួន ដើម្បីឲ្យកូនក្ដីខ្ញុំបាទមានឱកាសក្នុងការចេញទៅកសាងជីវិតថ្មីដោយក្ដីអនុគ្រោះ។

**ផ្អែកតាមកិច្ចពិភាក្សាដេញដោល**

- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខ
- ក្រោយពីបានស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] សៀកលីវ
- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] បុប្ផា

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ឡាក់
- ក្រោយពីបានពិនិត្យកស្តុតាងជាឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌
- ក្រោយពីបានស្តាប់ការកត់សម្គាល់របស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់

## សំអាងហេតុ

- ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២១០២ ពស.ព្រស/ច ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សុខ ជម្រះពីបទៈ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **សុខ** បានឆ្លើយសារភាពថា ៖ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ ២០២២ ខ្លួនបានរុញប្រពន្ធរបស់ខ្លួនធ្លាក់ពីលើកាំជណ្ដើរបណ្ដាលឲ្យប្រពន្ធដួលលើការ៉ូ ហើយខ្លួនបានយកកាំបិតប៉ុងតោនៅចង្ក្រានកាប់ត្រង់កជាច្រើនកាំបិតបណ្ដាលឲ្យស្លាប់តែម្ដង។ ខ្លួនមិនមានគំនិតគុំគួន ឬ មានការរៀបចំគម្រោង ឬ ផែនការគិតទុកជាមុនថានឹងសម្លាប់ប្រពន្ធនោះទេ ដោយសារខ្លួនមានអារម្មណ៍មួរម៉ៅ និងមានជម្ងឺរ៉ាំរ៉ៃផ្សេងៗធ្វើឲ្យខ្លួនទប់អារម្មណ៍មិនបានទើបឈានដល់ការធ្វើបែបនេះតែម្ដង។

- ពេលសវនាការសាក្សីឈ្មោះ [redacted] **សៀកលីវ** បានឆ្លើយបំភ្លឺថា៖ ខ្លួនត្រូវជាម្តាយរបស់ឈ្មោះ [redacted] សុខ កូនប្រុសរបស់ខ្លួនមានជម្ងឺរ៉ាំរ៉ៃច្រើនណាស់ ដូចជាជម្ងឺថ្លើម ជម្ងឺក្រពះ ជម្ងឺសរសៃប្រសាទ។ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ អ្នកជិតខាងរបស់កូនប្រុសរបស់ខ្លួនបានជិះម៉ូតូមកប្រាប់ថាកូនប្រុសរបស់ខ្លួនបានសម្លាប់ប្រពន្ធរបស់គេហើយខ្លួនក៏បានទៅដល់កន្លែងកើតហេតុ ក៏ឃើញមានសាកសពកូនប្រសារឈ្មោះ [redacted] គឹមហ៊ាង ពិតជាស្លាប់មែន។

- តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **ឡាក់** បានឆ្លើយបំភ្លឺនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលចៅក្រមស៊ើបសួរថា៖ នៅអំឡុងឆ្នាំ២០២២ កូនស្រីរបស់ខ្លួនឈ្មោះ [redacted] គឹមហ៊ាង បានប្រាប់ខ្លួនថា កូនប្រសាររបស់ខ្លួនឈ្មោះ [redacted] សុខ មានបញ្ហាវើវាយទើបក្រុមគ្រួសារបាននាំកូនប្រសារឈ្មោះ [redacted] សុខ មានបញ្ហាសតិអារម្មណ៍មិនប្រក្រតីហើយគ្រូពេទ្យប្រាប់ថាកូនប្រសាររបស់ខ្លួនឈ្មោះ [redacted] សុខ មានបញ្ហាសតិអារម្មណ៍មិនប្រក្រតីតែពុំសូវធ្ងន់ធ្ងរនោះទេ។ លុះដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ខ្លួនបានទូរស័ព្ទទៅកូនស្រីរបស់ខ្លួនឈ្មោះ [redacted] គឹមហ៊ាង តែមិនអាចទាក់ ទងបានខ្លួនក៏បានឲ្យកូនស្រីរបស់ខ្លួនម្នាក់ទៀតឈ្មោះ [redacted] គឹមឡាយ ទៅមើលផ្ទះបន្តិចក្រោយមកកូនស្រីរបស់ខ្លួនឈ្មោះ សោ គឹមឡាយ បានទូរស័ព្ទប្រាប់ថាកូនស្រីរបស់ឈ្មោះ [redacted] គឹមហ៊ាង ត្រូវបានប្តីឈ្មោះ [redacted] សុខ សម្លាប់នៅក្នុងផ្ទះតែម្ដង។ ខ្លួនមិនតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ហើយខ្លួនក៏មិនទាមទារសំណងអ្វីនោះដែរ។

- តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **បុប្ផា** បានឆ្លើយបំភ្លឺនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ខ្លួនបានឮ



Scanned with CamScanner

- វត្ថុចាប់យក

ក/-កូនកាំបិតចុងស្រួច ចំនួន ០១ (មួយ) ដងជ័រ ពណ៌ខ្មៅ។

ខ/-កាំបិតប៉ុងតោ ចំនួន ០១(មួយ) ដងឈើ។

គ/-កាំបិតចិតបន្លែចំនួន ០១(មួយ) ដងដែក។

គឺជាវត្ថុតាងនៃបទល្មើស គប្បីតុលាការសម្រេចរឹបអូស ស្របតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

**១-ផ្តន្ទាទោស ៖**

ឈ្មោះ [redacted] សុខ ភេទប្រុស កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ (អាយុ៤៦ឆ្នាំ) ជនជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ស្រេង "ស" ម្តាយឈ្មោះ [redacted] សៀកលីវ "រ" ប្រពន្ធឈ្មោះ [redacted] គឹមហ៊ាង "ស" ទោសពីមុន៖ គ្មាន **ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) ឆ្នាំ។**

ពីបទ ៖ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

**២**- វត្ថុចាប់យក

ក/-កូនកាំបិតចុងស្រួច ចំនួន ០១ (មួយ) ដងជ័រ ពណ៌ខ្មៅ។

ខ/-កាំបិតប៉ុងតោ ចំនួន ០១(មួយ) ដងឈើ។

គ/-កាំបិតចិតបន្លែចំនួន ០១(មួយ) ដងដែក។

គឺជាវត្ថុតាងនៃបទល្មើស តុលាការសម្រេចរឹបអូស ស្របតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

**៣**- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- | --- |

ហត្ថលេខា និងត្រា: [redacted]

**បានឃើញ**

ថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សា**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner